ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៥៩/២០ - ខេមបូឌា អ៊ែរផត មែនីជមែន ស៊ីវីស(CAMS)
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០
យោបល់ជំទាស់ទៅនឹងសេចក្ដីបង្គាប់ ៖ ដោយអាជ្ញាកណ្ដាល ខូន ស៊ីផាន់

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **លី តៃសេង**
អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ខូន ស៊ីផាន់**
ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជមែន ស៊ីវីស(CAMS)**
អាសយដ្ឋាន ៖ ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៦១ ២២២ ១០២ , ០៦១ ២២២ ១២០ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ផន ដា | ប្រធានផ្នែកធនធានមនុស្ស |
| ២- លោក មុំ ម៉េងឈុន | ប្រធានផ្នែកច្បាប់ |
| ៣- លោក ជីវ សាលីនឌី | ប្រធានផ្នែកធនធានមនុស្ស |
| ៤- លោក ហេង បូតេ | ជំនួយការផ្នែកធនធានមនុស្ស |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ**
- **សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប**

អាសយដ្ឋាន ៖ ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៩៧៨ ០០៧ / ០១២ ៩០៨ ៨៩១ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក នៃ រ៉ាវ៉ាន់ | ប្រធានសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប |

| | |
|---|---|
| ២- លោក សូ សៅហឿន | ប្រធានសហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ |
| ៣- លោក ព្រិត សុអួត | មន្ត្រីច្បាប់មជ្ឈមណ្ឌលអាមេរិកកាំង សម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS) |
| ៤- លោក ខឹម រតនា | មន្ត្រីច្បាប់មជ្ឈមណ្ឌលអាមេរិកកាំង សម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS) |
| ៥- លោក ដួង វាសនា | មន្ត្រីច្បាប់សហភាពការងារកម្ពុជា (CLC) |
| ៦- លោក ឌីន មករា | ជំនួយការច្បាប់សហភាពការងារកម្ពុជា (CLC) |
| ៧- លោក ធន សុងឃុយ | បុគ្គលិកសហភាពការងារកម្ពុជា (CLC) |
| ៨- លោក លាង ប៊ុនហេន | អនុប្រធានសហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ |
| ៩- លោក ណាន ច័ន្ទថន | លេខាសហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ |
| ១០-លោក ស សុហ៊ីម | លេខាសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប |
| ១១-លោក ប៊ី វាសនា | លេខារងសហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សហជីពដែលមានភាពជាតំណាងបំផុតប្រចាំព្រលានយន្តហោះអន្តរជាតិភ្នំពេញ និងសៀមរាប ទាមទារសុំឱ្យក្រុមហ៊ុនយកអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ មកបន្តអនុវត្តឡើងវិញ រយៈពេលបីឆ្នាំបណ្ដោះអាសន្ន ចាប់ពីឆ្នាំ២០២០-២០២២ ទាំងអត្ថប្រយោជន៍ និងលក្ខខណ្ឌការងារ និងប្រតិសកម្មអនុសញ្ញារួម ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ តទៅ។ ដោយឡែក តំណាងក្រុមហ៊ុនបានបញ្ជាក់ថា ចំពោះការស្នើសុំឱ្យមានការយកអនុសញ្ញារួមឆ្នាំ២០១៤-២០១៦ចាស់ មកបន្តប្រើថ្មីតាមការទាមទារនោះ គឺក្រុមហ៊ុនមិនអាចយកមកបន្តប្រើបានទេ ដោយសារថា អនុសញ្ញារួមនេះបានផុតលេត់តាំងពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រួចទៅហើយ ការផុតលេត់នេះ គឺខាងសហជីពជាអ្នកស្នើសុំក្រុមហ៊ុនមុនពេលអនុសញ្ញារួមនេះដាច់ ឬផុតកំណត់ គឺសហជីពបានដាក់លិខិតស្នើសុំបដិសេធមិនយកអនុសញ្ញារួមចាស់នេះយកមកប្រើកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ដូច្នេះ អនុសញ្ញារួមចាស់នេះ ក្រុមហ៊ុនមិនអាចយកមកអនុវត្តបានឡើយ។ បន្ថែមពីលើនេះ លោកតំណាងក្រុមហ៊ុនបានបញ្ជាក់ថា ថ្វីត្បិតតែក្នុងរយៈពេលបីឆ្នាំនេះមិនមានអនុសញ្ញារួមថ្មីអនុវត្តក៏ដោយ ក៏ក្រុមហ៊ុនបានបំពេញតួនាទីជានិយោជកល្អរួចទៅហើយ ដោយបានតម្លើងប្រាក់ខែជូនបុគ្គលិកទាំងអស់របស់ខ្លួន ក្នុងឆ្នាំ២០១៧ តម្លើង ១០ដុល្លារ, ឆ្នាំ២០១៨ តម្លើង ១០ដុល្លារ បូកBonus ១០ដុល្លារ និងឆ្នាំ២០១៩ តម្លើង ១៥ដុល្លារ បូក Bonus ៥ដុល្លារ។

២- សហជីពដែលមានភាពតំណាងបំផុតទាំងពីរ ទាមទារសុំឱ្យក្រុមហ៊ុនដាក់បញ្ចូលទៅក្នុងអនុសញ្ញារួម នូវសេវាភ្នាក់ងារប្រើប្រាស់អនុសញ្ញារួមចំពោះបុគ្គលិកដែលមិនមែនជាសមាជិករបស់សហជីពខ្លួន យ៉ាងតិចស្មើ ភាគទានដែលសមាជិកសហជីពបានបង់ចូលសហជីពរៀងរាល់ខែ ដែលចំណុចទាមទារនេះ ផ្អែកតាមមាត្រា ២៦ នៃច្បាប់ស្តីពីសហជីព ត្រង់កថាខណ្ឌទី២ នៃមាត្រានេះ និងប្រកាសលេខ ៣០០ ត្រង់ប្រការ៧។ ដោយ ឡែក ភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ចំពោះការស្នើសុំឱ្យក្រុមហ៊ុនដាក់បញ្ចូលទៅក្នុងអនុសញ្ញារួម នូវសេវា ភ្នាក់ងារ ក្រុមហ៊ុនឯកភាពអនុវត្តតាមប្រកាសលេខ ៣០០ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨។ ការអនុវត្តនេះ អាច ធ្វើទៅបាន គឺអាស្រ័យលើភាគីសាមីខ្លួនឯកភាពឱ្យក្រុមហ៊ុនកាត់លុយបង់ចូលក្នុងតម្លៃសេវានេះ ឬអត់ ក្រុមហ៊ុន មិនអាចធ្វើស្រេចចិត្តដោយគ្មានការយល់ព្រមពីសាមីខ្លួនបានឡើយ។

៣- សហជីពដែលមានភាពតំណាងបំផុតទាំងពីរ ទាមទារសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល និងប្រាក់ ឧបត្ថម្ភខែទី១៣ មួយរយភាគរយ រួមទាំងអត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិតដែលមិនបានចុះហត្ថលេខា ទទួលយកកិច្ចព្រមព្រៀងប្តូរកិច្ចសន្យាថ្មី ដោយខុសច្បាប់ជាបន្តបន្ទាប់របស់ក្រុមហ៊ុន ព្រោះថាប្រាក់ឈ្នួល និង ប្រាក់ឧបត្ថម្ភខែទី១៣នេះ បុគ្គលិក ឬកម្មករនិយោជិតដែលមិនបានចុះហត្ថលេខាទទួលយកកិច្ចព្រមព្រៀងប្តូរ កិច្ចសន្យាថ្មី ទទួលបានប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភខែទី១៣ តែ ៥០ភាគរយ ប៉ុណ្ណោះ។ ដោយឡែក ភាគី តំណាងក្រុមហ៊ុនបញ្ជាក់ថា ចំពោះចំណុចពាក់ព័ន្ធនឹងការទាមទារប្រាក់ឈ្នួល ត្រូវបានដោះស្រាយនៅក្រុម-ប្រឹក្សាអាជ្ញាកណ្តាលម្តងរួចមកហើយ។ ចំពោះប្រាក់ឧបត្ថម្ភខែទី១៣ គឺក្រុមហ៊ុនមានការផ្តល់ជូនដោយបែងចែក ជាពីរដំណាក់កាលៈ

ទី១-ក្រុមហ៊ុនបើកជូននៅខែកុម្ភៈ រៀលរាល់ឆ្នាំ ចំនួន ៥០ភាគរយ នៃប្រាក់ឈ្នួលគោល និង

ទី២-បើកជូននៅខែសីហា ចំនួន ៥០ភាគរយ ដូចមានចែងក្នុងអនុសញ្ញារួម។

ការផ្តល់ប្រាក់ឧបត្ថម្ភនេះ ក្នុងស្ថានភាពកូវីដបច្ចុប្បន្ន គឺមានការកែសម្រួលថ្មីទៅលើការផ្តល់ជូនប្រាក់ឧបត្ថម្ភខែទី ១៣នេះ ចំពោះអ្នកដែលបានទទួលយកការប្តូរចនាសម្ព័ន្ធការងារថ្មី ដើម្បីឆ្លើយតបនឹងការរីករាលដាលកូវីដ១៩។ ចំពោះអ្នកដែលបានទទួលយកការផ្លាស់ប្តូរចនាសម្ព័ន្ធការងារថ្មីរបស់ក្រុមហ៊ុននេះ ក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភ ៨០ភាគរយ នៃប្រាក់ឈ្នួលគោលមធ្យម ចំពោះអ្នកដែលក្រុមហ៊ុនឱ្យសម្រាកនៅផ្ទះក្នុងស្ថានភាពកូវីដ រីឯអ្នកមក ធ្វើការជាប់លាប់ ក្រុមហ៊ុនផ្តល់ឱ្យ ១០០ភាគរយ។ ដោយឡែក ចំពោះបុគ្គលិកមិនទទួលយកការផ្លាស់ប្តូរចនា-សម្ព័ន្ធការងារថ្មីរបស់ក្រុមហ៊ុនទេ ក្រុមហ៊ុនក៏ផ្តល់ជូនដែរ តែចំនួន ៥០ភាគរយ ប៉ុណ្ណោះ។

គោលការណ៍ដែលក្រុមហ៊ុនមានគោលបំណងសំខាន់ចំនួន៤ ចំពោះបុគ្គលិកដូចខាងក្រោម៖

-សំដៅធានានិរន្តភាពក្រុមហ៊ុន និងការងាររបស់និយោជិត

-ធានានូវតម្រូវការអប្បបរមាសម្រាប់ការផ្តល់សេវាសាធារណៈនៅក្នុងអាកាសយានដ្ឋានយើង

-រក្សានិរន្តភាពចំណូលរបស់និយោជិត

-ប្រុងប្រៀបសម្រាប់ដំណើរការជាប្រក្រតីឡើងវិញក្រោយវិបត្តិកន្លងផុតទៅ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំង

THE ARBITRATION COUNCIL

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២(ក)នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា (CAMS) លេខ ១១០២ ក.ប/អក/វក ចុះថ្ងៃចន្ទ ៣កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃចន្ទ ១០កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០២ និង ០០។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា (CAMS) ស្តីពីការទាមទារសុំឱ្យក្រុមហ៊ុនដោះស្រាយលក្ខខណ្ឌការងារចំនួន ៣ចំណុច ឱ្យបានប្រសើរជូនកម្មករនិយោជិត។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះទៅតាមនីតិវិធីច្បាប់ និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ចំណុចវិវាទដែលមិនសះជាចំនួន ៣ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា(CAMS) លេខ ១១០២ ក.ប/អក/វក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ៣ចំណុចនេះ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៣ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

THE ARBITRATION COUNCIL

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ របស់លោក Philippe Araujo ជាអគ្គលេខាធិការ នៃក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា(ក្រុមហ៊ុន CAMS) ផ្ទេរសិទ្ធិជូនលោក ផន ដា, ជីវ សាលីនឌី, តែ ស្រីមុំ, មុំ ម៉េងឈុន ដើម្បីចូលរួមដំណើរការនីតិវិធីដោះស្រាយវិវាទការងារ។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មមែន សឺវីស លេខ MOC-២២១០៩២០៥ ពណ.ចបព ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៥។

៣- លិខិតចុះថ្ងៃចន្ទ ១០កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ជូនចំពោះក្រុមអាជ្ញាកណ្តាល នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជំហរ និង ទឡ្ហីករណ៍ របស់ភាគីក្រុមហ៊ុន ទៅលើការទាមទាររបស់ភាគីសហជីពក្នុងសំណុំរឿងលេខ ០៥៩/២០។

៤- លិខិតបដិសេធអនុសញ្ញារួមចាស់ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ របស់ថ្នាក់ដឹកនាំសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប, ថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតឯករាជ្យ នៃព្រលានយន្តហោះភ្នំពេញ, ថ្នាក់ដឹកនាំសហជីពនិយោជិតវិស័យទេសចរណ៍ នៃអាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ គោរពជូន លោកអគ្គនាយកក្រុមហ៊ុន អាកាសយានដ្ឋានកម្ពុជា ស្តីពីជំទាស់លើអនុសញ្ញារួមចាស់ ដែលនឹងត្រូវផុតកំណត់នៅបំណាច់ឆ្នាំ២០១៦ ហើយស្នើ ធ្វើអនុសញ្ញារួមថ្មី សម្រាប់ឆ្នាំ២០១៧ ដល់២០១៩។

៥- លិខិត(Internal Memorandum) ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មមែន សឺវីស ជូនដំណឹងចំពោះបុគ្គលិកទាំងអស់ ស្តីពីសេចក្តីសម្រេចរបស់ក្រុមហ៊ុន។

៦- លិខិត(Internal Memorandum) ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មមែន សឺវីស ជូនដំណឹងចំពោះបុគ្គលិកទាំងអស់ ស្តីពីសេចក្តីសម្រេចរបស់ក្រុមហ៊ុន។

៧- លិខិត(Internal Memorandum) ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មមែន សឺវីស ជូនដំណឹងចំពោះបុគ្គលិកទាំងអស់ ស្តីពីសេចក្តីសម្រេចរបស់ក្រុមហ៊ុន។

៨- ច្បាប់ស្តីពីសហជីព ទំព័រ១៤។

៩- ប្រកាសលេខ ៣០០ ក.ប/ប្រ.ក.ក.ប.ក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សោហ៊ុយភ្នាក់ងារ។

THE ARBITRATION COUNCIL

១០- លិខិត(Internal Memorandum) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មមែន សឺវីស ជូនដំណឹងចំពោះបុគ្គលិកក្រុមហ៊ុនទាំងអស់ ស្តីពីរចនាសម្ព័ន្ធការងាររបស់ក្រុមហ៊ុនដើម្បីឆ្លើយតបនឹងការរីករាលដាលនៃវីរុស កូវីដ-១៩។

១១- លិខិត(Internal Memorandum) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរ ផត មែនីជ្មមែន សឺវីស ជូនដំណឹងចំពោះបុគ្គលិកក្រុមហ៊ុនទាំងអស់ ស្តីពីការបន្តអនុវត្តរចនាសម្ព័ន្ធការងារថ្មីរបស់ក្រុមហ៊ុន ដើម្បីឆ្លើយតបនឹងការរីករាលដាលនៃមេរោគកូវីដ-១៩។

១២- លិខិត(Internal Memorandum) ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរ ផត មែនីជ្មមែន សឺវីស ជូនដំណឹងចំពោះបុគ្គលិកក្រុមហ៊ុនទាំងអស់ ស្តីពីការបន្តអនុវត្តរចនាសម្ព័ន្ធការងារថ្មីរបស់ក្រុមហ៊ុន ដើម្បីឆ្លើយតបនឹងការរីករាលដាលនៃមេរោគកូវីដ-១៩ និងការស្នើសុំឈប់ពីការងារដោយស្ម័គ្រចិត្ត។

១៣- សេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០២៨/២០-អាកាសយានដ្ឋានកម្ពុជា(CAMS) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ ទំព័រ ៣៨ និង៣៩។

១៤- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មមែន សឺវីស ចុះទិដ្ឋាការលេខ ១៧២ កប.អក.អធក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ ដោយប្រធាននាយកដ្ឋានអធិការកិច្ចការងារ។

១៥- អនុសញ្ញារួម២០១៤-២០១៦ រវាងសហជីពកម្មករនិយោជិតឯករាជ្យអន្តរជាតិ ព្រលានយន្តហោះអន្តរជាតិ, សហជីពកម្មករឧស្សាហកម្ម ទេសចរណ៍កម្ពុជាព្រលានយន្តហោះសៀមរាប ជាមួយនឹង ក្រុមហ៊ុនបំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា ចុះបញ្ជិកាលេខ ៤៥៩ កប/អក/វក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤។

១៦- លិខិតចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មមែន សឺវីស គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើដាក់ឯកសារ និងបញ្ជាក់ពីជំហរបន្ថែម ក្នុងសំណុំរឿងលេខ ០៥៩/២០។

១៧- លិខិតចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មមែន សឺវីស ជម្រាបជូន ប្រធានសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប , ប្រធានសហជីពកម្មករនិយោជិតឯករាជ្យនៃព្រលានយន្តហោះភ្នំពេញ, ប្រធានសហជីពនិយោជិតវិស័យទេសចរណ៍ នៃអាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ ស្តីពីអនុសញ្ញារួម (២០១៤-២០១៦)។

១៨- លិខិតចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មមែន សឺវីស ជូនចំពោះប្រធានសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប, ប្រធានសហជីពកម្មករនិយោជិតឯករាជ្យ នៃព្រលានយន្តហោះភ្នំពេញ, ប្រធានសហជីពនិយោជិតវិស័យទេសចរណ៍ នៃអាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ ស្តីពីការអញ្ជើញចូលរួមក្នុងកិច្ចប្រជុំដំបូង ស្តីពីអនុសញ្ញារួម(២០១៧-២០១៩)។

១៩- លិខិត(Internal Memorandum ) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្ជមែន សឺវីស ជូនចំពោះបុគ្គលិកក្រុមហ៊ុនទាំងអស់ ស្តីពីលទ្ធផលនៃការប្រជុំបឋម ជាមួយថ្នាក់ដឹកនាំសហជីពស្តីពីអនុសញ្ញារួមអាណត្តិទី៥។

២០- លិខិតចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្ជមែន សឺវីស ជូនចំពោះ ប្រធានសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប, ប្រធានសហជីពកម្មករនិយោជិតឯករាជ្យ នៃព្រលានយន្តហោះភ្នំពេញ, ប្រធានសហជីពនិយោជិតវិស័យទេសចរណ៍ នៃអាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ ស្តីពីការចរចារអនុសញ្ញារួមអាណត្តិទី៥ (២០១៧-២០១៩)។

២១- លិខិតចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្ជមែន សឺវីស ជូនចំពោះ ប្រធានសហជីពកម្មករនិយោជិតឯករាជ្យ នៃព្រលានយន្តហោះភ្នំពេញ, ប្រធានសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប, ប្រធានសហជីពនិយោជិតវិស័យទេសចរណ៍ នៃអាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ ស្តីពីការអញ្ជើញចូលរួមចរចារកិច្ចព្រមព្រៀងរបស់ក្រុមហ៊ុនដែលមានតម្លៃស្មើអនុសញ្ញារួម។

២២- លិខិត(Internal Memorandum ) ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្ជមែន សឺវីស ជូនចំពោះបុគ្គលិកទាំងអស់ ស្តីពីលទ្ធផលនៃកិច្ចពិភាក្សាជាមួយសហជីពស្តីពីអនុសញ្ញារួមថ្មី។

២៣- លិខិតចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្ជមែន សឺវីស ជូនចំពោះ ប្រធានសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជាព្រលានយន្តហោះសៀមរាប, ប្រធានសហជីពកម្មករកម្ពុជា, ប្រធានសហជីពនិយោជិតនៃក្រុមហ៊ុន ព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុ និង ប្រតិភូពេញសិទ្ធិ៣រូប ប្រចាំអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ស្តីពីការអញ្ជើញចូលប្រជុំពិគ្រោះយោបល់ស្តីពីអនុសញ្ញារួមនៅថ្ងៃអនាគត។

២៤- លិខិតចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្ជមែន សឺវីស ជូនចំពោះ ប្រធានសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជាព្រលានយន្តហោះសៀមរាប, ប្រធានសហជីពកម្មករកម្ពុជា, ប្រធានសហជីពនិយោជិតនៃក្រុមហ៊ុន ព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុ និង ប្រតិភូពេញសិទ្ធិ៣រូប ប្រចាំអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ស្តីពីការអញ្ជើញចូលប្រជុំពិគ្រោះយោបល់លើកទី២ស្តីពីអនុសញ្ញារួមនៅថ្ងៃអនាគត។

២៥- លិខិតលេខ ០០១២/១៨.សកឧទកពស. ចុះថ្ងៃចន្ទ ១២រោច ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ របស់សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជាព្រលានយន្តហោះសៀមរាប គោរពជូន អគ្គលេខាធិការក្រុមហ៊ុនអាកាសយានដ្ឋានអន្តរជាតិកម្ពុជា ស្តីពីការឆ្លើយតបលិខិតអញ្ជើញចូលរួមប្រជុំពិគ្រោះយោបល់លើកទី២ ស្តីពីអនុសញ្ញារួមនៅថ្ងៃអនាគត។

២៦- លិខិតលេខ ០១២៧.សកឧទកពស. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៧ របស់សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប គោរពជូន លោក ហ្វ្រាំងស័រ

THE ARBITRATION COUNCIL

វីស៊ើស ឡឺមីញែរ អគ្គលេខាធិការ នៃក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា ស្តីពីការឆ្លើយតបលិខិតរបស់លោកអគ្គលេខាធិការស្តីពីការចរចារអនុសញ្ញារួមថ្មីអាណត្តិទី៥។

២៧- លិខិត ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា និងសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជាព្រលានយន្តហោះសៀមរាប គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីសំណើសុំភាពជាតំណាងបំផុតរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត។

២៨- លិខិតចុះថ្ងៃសុក្រ ៦រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ២០២០ ជូនចំពោះក្រុមអាជ្ញាកណ្តាល នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំជំទាស់ឯកសារ និងហេតុផលរបស់ភាគីសហជីពក្នុងសំណុំរឿងលេខ ០៥៩/២០។

២៩- សេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០០៥/២០-អាកាសយានដ្ឋានអន្តរជាតិសៀមរាប ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ទំព័រ ១ និង២៤។

៣០- បញ្ជីឈ្មោះបុគ្គលិកនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ, បុគ្គលិកដែលក្រុមហ៊ុនបញ្ឈប់ដោយបានប្រព្រឹត្តកំហុស, បុគ្គលិកដែលសុំឈប់ពីការងារដោយស្ម័គ្រចិត្ត, បុគ្គលិកសុំចូលនិវត្ត, បុគ្គលិកដែលកំពុងរង់ចាំការយល់ព្រមឈប់សម្រាកពីការងារដោយស្ម័គ្រចិត្ត, បុគ្គលិកកំពុងរង់ចាំការយល់ព្រមឱ្យឈប់សម្រាកដោយស្ម័គ្រចិត្ត, បុគ្គលិកកំពុងនៅបំរើការងារនៅឡើយ និងឈ្មោះមិនមានក្នុងបញ្ជីក្រុមហ៊ុន។

៣១- លិខិតស្នើសុំឈប់ពីការងារ ដោយស្ម័គ្រចិត្ត របស់ឈ្មោះ HENG DARA, CHUM THAVY, KEO PISEY, KHIM LIDA, MAM SOKVUTHY, UN SOKCHEA, BUN SINEANG, NGIM TOUCH និង PICH RITHY។

៣២- លិខិតស្នើសុំលាឈប់ របស់ឈ្មោះ កែវ ស៊ីថន, សៅ ស៊ីផាត, អ៊ុន ប៊ុនណាត, ប៊ី សាំងហ៊ា និង វ៉ា ផលវាសនា។

៣៣- លិខិតរបស់ឈ្មោះ ហាម វណ្ណៈ, ម៉ែន គឹមលី និង នាក់ សារិទ្ធិ ជូនចំពោះប្រធានផ្នែកធនធានមនុស្ស ស្តីពីការស្នើសុំឈប់ពីការងារដោយស្ម័គ្រចិត្តក្នុងពេលរីករាលដាលវីរុសកូវីដ១៩។

៣៤- ពាក្យស្នើសុំចូលនិវត្តន៍ របស់ឈ្មោះ កែវ ជឿន, កែវ រិន និង ជា គឿន។

៣៥- ពាក្យស្នើសុំគោលការណ៍គណនាប្រាក់ចូលនិវត្តក្នុងកម្មវិធីការរីករាលដាលវីរុសកូវីដ១៩ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២០ របស់ ឈ្មោះ នូ សោភា។

៣៦- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មែន ស៊ើវីស ទំព័រ១០ និង ១១។

៣៧- បញ្ជីឈ្មោះកម្មករនិយោជិតចំនួន ៥៩នាក់ ដែលទាមទារប្រាក់ឧបត្ថម្ភខែទី១៣ និងប្រាក់ឧបត្ថម្ភអត្ថប្រយោជន៍ផ្សេងៗ(ថ្លៃអាហារ ៩០ដុល្លារ និងប្រាក់ជួសធ្វើការថ្ងៃបុណ្យជាតិ)១០០% អំឡុងពេលមានការកែប្រែ ឬ និង ព្យួរកិច្ចសន្យាការងារដោយខុសច្បាប់។

៣៨- បញ្ជីឈ្មោះកម្មករនិយោជិតចំនួន ១៥នាក់ ដែលទាមទារប្រាក់ឧបត្ថម្ភខែទី១៣ និងប្រាក់ឧបត្ថម្ភ អត្ថប្រយោជន៍ផ្សេងៗ(ថ្លៃអាហារ ៩០ដុល្លារ និងប្រាក់ជួសធ្វើការថ្ងៃបុណ្យជាតិ)១០០% អំឡុងពេលមានការកែប្រែ ឬ និង ព្យួរកិច្ចសន្យាការងារដោយខុសច្បាប់។

៣៩- ឯកសារភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចាត់តាំងលេខ ០២៦/២០ ACILS ចុះថ្ងៃចន្ទ ១០កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ របស់មជ្ឈមណ្ឌលអាមេរិកកាំង សម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS) ស្តីពីការចាត់តាំងលោក ព្រិត សុអួត និង ខឹម រតនា ជាមន្ត្រីច្បាប់ ដើម្បីចូលរួមដោះស្រាយសំណុំរឿងវិវាទការងាររួម នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២- លិខិតរបស់សហព័ន្ធសហជីពកម្មករ វិស័យដឹកជញ្ជូនកម្ពុជា លេខ ០០១២.ស.ជ.ក គោរពជូន លោក វិលលៀម ខនគ្លីន នាយកមជ្ឈមណ្ឌលអាមេរិកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS/SC) ស្តីពីការស្នើសុំមន្ត្រី និងផ្ទេរសិទ្ធិជូនលោក ព្រិត សុអួត ដើម្បីជួយអម និងដោះស្រាយគ្រប់នីតិវិធី នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។

៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះ សៀមរាប លេខ ០០២ ម.ក.ប ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧។

៤- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប លេខ ០២២/១៩ក.ប/វ.ប.វ.ក ចុះថ្ងៃសុក្រ ១៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩។

៥- លិខិតលេខ ០០២ ម.ក.ប ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

៦- អនុសញ្ញារួម២០១៤-២០១៦ រវាងសហជីពកម្មករនិយោជិតឯករាជ្យអន្តរជាតិ ព្រលានយន្តហោះអន្តរជាតិ, សហជីពកម្មករឧស្សាហកម្ម ទេសចរណ៍កម្ពុជាព្រលានយន្តហោះសៀមរាប ជាមួយនឹងក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា ចុះបញ្ជិកាលេខ ៤៥៩ កប/អក/វក ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៤។

៧- លិខិតលេខ ០២០/១៩.សកឧទកពស. ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ របស់សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប គោរពជូន អគ្គនាយកក្រុមហ៊ុនអាកាសយានដ្ឋានអន្តរជាតិកម្ពុជា ស្តីពីការស្នើសុំចរចាអនុសញ្ញារួមថ្មី ឆ្នាំ២០១៩-២០២១។

៨- វិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួមថ្មីរវាង ក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា និងសហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ និងសហ

THE ARBITRATION COUNCIL

ជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៩។

៩- កិច្ចព្រមព្រៀងរវាងភាគីនិយោជក ជាមួយនឹងសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប និងសហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ សំណុំរឿងលេខ ០០៦/២០ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

១០-លិខិតចុះថ្ងៃចន្ទ ៧កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផត មេនីជ្ជមែន សឺវីស ជូនចំពោះ លោក សូ សៅហឿន ស្តីពីការព្យួរការចរចាអនុសញ្ញារួម។

១១- តារាងបញ្ជាក់ប្រាក់ចំណូលរបស់ Vinci Group ចេញផ្សាយដោយ នាយកដ្ឋានស្រាវជ្រាវ Statista នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០។

១២- សេចក្តីអំពាវនាវ ស្តីពីការអនុវត្តការព្យួរកិច្ចសន្យាការងារសម្រាប់វិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូប ដែលរងផលប៉ះពាល់ពីកង្វះខាតវត្ថុធាតុដើម ដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរកូវីដ-១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃសុក្រ ១៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០២០។

១៣- សេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០២៨/២០-អាកាសយានដ្ឋានកម្ពុជា(CAMS) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ ទំព័រ ៣៨ និង៣៩។

១៤- ប្រកាសលេខ ៣០០ ក.ប/ប្រ.ក.ក.ប.ក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ។

១៥- សារណារបស់សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប និងសហជីពកម្មករនិយោជិត ឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ ចុះថ្ងៃពុធ ១២កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០។

១៦- លិខិតលេខ ៣០៨ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក ប្រធានសហជីពកម្មករនិយោជិត ឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ ស្តីពីការការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី៧។

១៧- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពកម្មករកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ លេខ ៣៣០ ក.ប/វ.ប.វ.ក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨។

១៨- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត សហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិ ភ្នំពេញ លេខ ០៩៤/១៩ ក.ប/វ.ប.វ.ក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។

១៩- សេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០០៥/២០-អាកាសយានដ្ឋានកម្ពុជា(CAMS) ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ទំព័រ ០១ និង២៥។

THE ARBITRATION COUNCIL

២០- លិខិតចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផេត មែនីជ្ជមែន ស៊ីវីស ជម្រាបជូន លោក សូ សៅហឿន ស្ដីពីលិខិតព្រមាន។

២១- លិខិតចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផេត មែនីជ្ជមែន ស៊ីវីស ជម្រាបជូន លោក ឈឹម សុភ័ណ្ឌ ស្ដីពីលិខិតព្រមាន។

២២- លិខិតចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផេត មែនីជ្ជមែន ស៊ីវីស ជម្រាបជូន លោក សុខ ៣៧ ស្ដីពីការបណ្ដេញចេញពីការងារ។

២៣- លិខិតចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផេត មែនីជ្ជមែន ស៊ីវីស ជម្រាបជូន លោក ឯក សំបូរ ស្ដីពីការបណ្ដេញចេញពីការងារ។

២៤- បញ្ជីឈ្មោះកម្មករនិយោជិតដែលលាឈប់ពីការងារអំឡុងពេលព្យួរកិច្ចសន្យា។

២៥- លិខិត(Internal Memorandum) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផេត មែនីជ្ជមែន ស៊ីវីស ជម្រាបជូនបុគ្គលិកក្រុមហ៊ុនទាំងអស់ ស្ដីពីការជូនដំណឹងចំពោះនិយោជិត ស្ដីពីរចនាសម្ព័ន្ធការងាររបស់ក្រុមហ៊ុន ដើម្បីឆ្លើយតបនឹងការរីករាលដាលនៃវីរុស កូវីដ-១៩។

២៦- លិខិតចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផេត មែនីជ្ជមែន ស៊ីវីស ផ្ញើជូនលោក វ៉ន វ៉ាក់ ស្ដីពីការអនុវត្តរចនាសម្ព័ន្ធការងារថ្មីដែលបណ្ដាលមកពីជម្ងឺកូវីដ-១៩ (Covid-19)។

២៧- លិខិតសម្រាប់ផែនការនៃការអនុញ្ញាតឱ្យឈប់សម្រាក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ខេមបូឌា អ៊ែរផេត មែនីជ្ជមែន ស៊ីវីស ផ្ញើជូន ឈ្មោះ ហ៊ិន ប៊ុនចន្ថុល។

២៨- បញ្ជីឈ្មោះកម្មករនិយោជិតចំនួន ៥៩នាក់ ដែលទាមទារប្រាក់ឧបត្ថម្ភខែទី១៣ និងប្រាក់ឧបត្ថម្ភអត្ថប្រយោជន៍ផ្សេងៗ(ថ្លៃអាហារ ៩០ដុល្លារ និងប្រាក់ជួសធ្វើការថ្ងៃបុណ្យជាតិ)១០០% អំឡុងពេលមានការកែប្រែ ឬ និង ព្យួរកិច្ចសន្យាការងារដោយខុសច្បាប់។

២៩- បញ្ជីឈ្មោះកម្មករនិយោជិតចំនួន ១៥នាក់ ដែលទាមទារប្រាក់ឧបត្ថម្ភខែទី១៣ និងប្រាក់ឧបត្ថម្ភអត្ថប្រយោជន៍ផ្សេងៗ(ថ្លៃអាហារ ៩០ដុល្លារ និងប្រាក់ជួសធ្វើការថ្ងៃបុណ្យជាតិ)១០០% អំឡុងពេលមានការកែប្រែ ឬ និង ព្យួរកិច្ចសន្យាការងារដោយខុសច្បាប់។

៣០- លិខិតជំទាស់ របស់សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប និងសហជីពកម្មករនិយោជិត ឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ ចុះថ្ងៃសុក្រ ៦រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០ គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីបដិសេធកស្ដុតាង និងទឡ្ហីករណ៍របស់ក្រុមហ៊ុន ចុះថ្ងៃទី២៦ និង២៨ ខែតុលា ឆ្នាំ២០២០។

៣១- ឯកសារស្ដីពីស្ថានភាពអតិផរណានៅខែមេសា ឆ្នាំ២០១៩ ចេញពីប្រភព នៃវិទ្យាស្ថានជាតិស្ថិតិ (NIS)។

៣២- ឯកសារជាភាសាបរទេស។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា(CAMS) លេខ ១១០២ **ក.ប**/អក/វក ចុះថ្ងៃចន្ទ ៣កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា(CAMS) ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០។

៣- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត របស់សហជីពកម្មករនិយោជិត ឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ លេខ ០៩៤/១៩ ក.ប/វ.ប.វក ចុះថ្ងៃ សុក្រ ១០កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៦៧ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ៤កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៦៨ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ៤កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ខេមូឌា អ៊ែរផត មែនីជ្ជមែន សឺវីស គឺជាក្រុមហ៊ុនមានសកម្មភាពចម្បងផ្នែកសេវាគ្រប់គ្រងអាកាសយាន្តដ្ឋានអន្តរជាតិ និងទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០០៩៨៦២ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩៥។
- យោងតាមរបាយការណ៍ដោះស្រាយវិវាទការងាររួម និងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មខាងលើ ក្រុមហ៊ុន ខេមូឌា អ៊ែរផត មែនីជ្ជមែន សឺវីស និងក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា (CAMS) គឺជាក្រុមហ៊ុនតែមួយ តទៅនេះ ហៅថា ក្រុមហ៊ុន ខេមូឌា អ៊ែរផត មែនីជ្ជមែន សឺវីស។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបចំនួន ១៣១៥នាក់។ *(យោងតាមរបាយការណ៍ ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា(CAMS))*
- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត សហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ លេខ ១១២១៨០៤៥៤ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៨។
- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជានៃព្រលានយន្តហោះសៀមរាប លេខ ១១៧១៧០០០២ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកយកអនុសញ្ញារួមចាស់ឆ្នាំ២០១៤-២០១៦ មកបន្ត អនុវត្តឡើងវិញរយៈពេលបីឆ្នាំបណ្តោះអាសន្ន ចាប់ពីឆ្នាំ២០២០-២០២២ ទាំងអត្ថប្រយោជន៍ និងលក្ខខណ្ឌការងារ និងប្រតិសកម្មអនុសញ្ញារួមចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ តទៅ**

- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - នៅក្នុងក្រុមហ៊ុន មានអនុសញ្ញារួមចាស់ឆ្នាំ២០១៤-២០១៦ មានចិរវេលាកំណត់ចំនួន ៣ឆ្នាំ គឺចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។
  - នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ភាគីកម្មករនិយោជិតបានដាក់លិខិតបដិសេធអនុសញ្ញារួមចាស់ឆ្នាំ២០១៤-២០១៦នេះ និងស្នើសុំឱ្យនិយោជកចរចាអនុសញ្ញារួមថ្មី។
  - បច្ចុប្បន្នភាគីទាំងពីរកំពុងនៅក្នុងនីតិវិធីចរចាអនុសញ្ញារួម ប៉ុន្តែ មិនទាន់ឈានដល់កិច្ចព្រមព្រៀងលើអនុសញ្ញារួមថ្មីនោះទេ។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - យោងតាមមាត្រា ៥១ នៃច្បាប់ស្តីពីសហជីព ភាគីនិយោជកមានភាពមិនស្មោះត្រង់ និងមិនមានភាពសុចរិតក្នុងការចរចាអនុសញ្ញារួមថ្មី ដោយហេតុថា និយោជកបានពន្យារពេល និងបានព្យួរការចរចាអនុសញ្ញារួមថ្មីដោយគ្មានការឯកភាពពីកម្មករនិយោជិត និងមិនបានកំណត់ពេលវេលាឱ្យបានច្បាស់លាស់ក្នុងការចរចាអនុសញ្ញារួមថ្មីនោះទេ។
  - និយោជកអនុវត្តផ្ទុយពីមាត្រា ៦៣ នៃច្បាប់ស្តីពីសហជីព ដោយមានការរារាំង និងមិនគោរពតាមកិច្ចព្រមព្រៀងដែលបានកំណត់ ដោយហេតុថា និយោជកបានឯកភាពនៅក្នុងវិធានផ្ទៃក្នុងការចរចាអនុសញ្ញារួមថ្មីឱ្យចប់នៅចុងឆ្នាំ២០១៩ និងបានចុះកិច្ចព្រមព្រៀងជាមួយកម្មករនិយោជិតក្នុងការចរចាអនុសញ្ញារួមថ្មីឱ្យចប់នៅក្នុងខែមេសា ឆ្នាំ២០២០ ប៉ុន្តែ និយោជកមិនបានអនុវត្តតាមការកំណត់នោះទេ។ ម្យ៉ាងទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីសម្រេចបង្គាប់ឱ្យនិយោជកចរចាអនុសញ្ញារួមថ្មីឱ្យចប់ក្នុងរយៈពេល ៣ខែយ៉ាងយូរ ផងដែរ ប៉ុន្តែ និយោជកនៅតែមិនព្រមអនុវត្ត។
  - ការចរចាអនុសញ្ញារួមថ្មី គឺមិនពាក់ព័ន្ធនឹងបញ្ហាជំងឺកូវីដ-១៩ នោះទេ ព្រោះការចរចាអនុសញ្ញារួមថ្មីនេះ គឺធ្វើឡើងចាប់តាំងពីពេលមិនទាន់មានបញ្ហាជំងឺកូវីដ-១៩។ និយោជកមិនមានវិបត្តិហិរញ្ញវត្ថុនោះទេ ដោយយោងតាមរបាយការណ៍អតិផរណា និងរបាយការណ៍ចំណូលចំណាយរបស់ក្រុមហ៊ុនប្រចាំឆ្នាំ២០១៧, ២០១៨, និង២០១៩ មានប្រាក់ចំណេញចំនួនរាប់លានអ៊ីរ៉ូ។
  - ម្យ៉ាងទៀត យោងតាមមាត្រា ៦៩ នៃច្បាប់ស្តីពីសហជីព លិខិតបដិសេធអនុសញ្ញារួមចាស់ឆ្នាំ២០១៤-២០១៦ របស់ភាគីកម្មករនិយោជិតមិនបានបដិសេធលើខ្លឹមសារអនុសញ្ញារួមដែលនិយោជកធ្លាប់បានផ្តល់ជូននោះទេ គឺបដិសេធតែលើបញ្ហានីតិវិធីតែប៉ុណ្ណោះ។ ម្យ៉ាងទៀត ដោយសារនិយោជកមិនមានឆន្ទៈក្នុងការចរចាអនុសញ្ញារួមថ្មីឱ្យចប់ ហេតុនេះ ហើយទើបកម្មករនិយោជិតទាមទារឱ្យនិយោជកអនុវត្តអនុសញ្ញារួមចាស់នេះតែម្តង។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - យោងតាមប្រការ ៣ អនុសញ្ញារួមឆ្នាំ២០១៤-២០១៦នេះ ត្រូវបានផុតសុពលភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ មកម្ល៉េះ ព្រោះនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ភាគីកម្មករ

THE ARBITRATION COUNCIL

និយោជិតបានដាក់លិខិតបដិសេធអនុសញ្ញារួមចាស់ឆ្នាំ២០១៤-២០១៦។ បន្ទាប់ពីនិយោជកបានទទួលលិខិតបដិសធនេះ និយោជកបានឆ្លើយតប និងបានអញ្ជើញភាគីកម្មករនិយោជិតមកប្រជុំពិភាក្សា ប៉ុន្តែ ភាគីកម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិតបានបដិសេធអនុសញ្ញារួមចាស់ឆ្នាំ២០១៤-២០១៦នេះ រួចហើយ។

 - ០ និយោជកចាត់ទុកថា លិខិតបដិសេធអនុសញ្ញារួមចាស់ឆ្នាំ២០១៤-២០១៦ គឺជាលិខិតបដិសេធអនុសញ្ញារួម មិនមែនជាលិខិតបដិសេធលើបញ្ហានីតិវិធីនោះទេ។

- យោងតាមឯកសាររបស់ភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖
  - ០ ប្រការ ៣.១ នៃអនុសញ្ញារួម ២០១៤-១០១៦ ចុះថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ បានកំណត់ថា ៖ *"អនុសញ្ញារួមនេះមានរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៤។ បើគ្មានការបដិសេធអនុសញ្ញារួមនេះក្នុងរយៈពេល ៣ខែ មុននឹងអនុសញ្ញារួមនេះអស់សុពលភាពទេ អនុសញ្ញារួមនេះនឹងនៅមានតម្លៃជាធរមានសំរាប់រយៈពេល១(មួយ)ឆ្នាំទៀត។"*
  - ០ លិខិតបដិសេធអនុសញ្ញារួមចាស់ របស់ថ្នាក់ដឹកនាំសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប, ថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតឯករាជព្រលានយន្តហោះអន្តរជាតិភ្នំពេញ និងថ្នាក់ដឹកនាំសហជីពនិយោជិតវិស័យទេសចរណ៍ នៃអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ បានបញ្ជាក់ថា ៖"... *កម្មវត្ថុ៖ ជំទាស់លើអនុសញ្ញារួមចាស់ ដែលនឹងត្រូវផុតកំណត់នៅបំណាច់ឆ្នាំ២០១៦ ហើយស្នើធ្វើអនុសញ្ញារួមថ្មីសំរាប់ឆ្នាំ២០១៧ ដល់២០១៩...សហជីពសុំជំទាស់លើអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ហើយមិនអាចអនុវត្តន៍បន្តទៀតបានទេ និងស្នើធ្វើអនុសញ្ញារួមថ្មីសំរាប់ឆ្នាំ២០១៧ ដល់២០១៩...សូមលោកអគ្គនាយក មេត្តាទទួលយកសេចក្តីជំទាស់ និងសំណើខាងលើរបស់តំណាងកម្មករនិយោជិតដោយក្តីអនុគ្រោះ..."*។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកដាក់បញ្ចូលទៅក្នុងអនុសញ្ញារួមនូវសេវាភ្នាក់ងារប្រើប្រាស់អនុសញ្ញារួមចំពោះបុគ្គលិកដែលមិនមែនជាសមាជិករបស់សហជីពខ្លួន យ៉ាងតិច ស្មើភាគទានដែលសមាជិកសហជីពបានបង់ចូលសហជីពរៀងរាល់ខែ ដែលចំណុចទាមទារនេះ ផ្អែកតាមមាត្រា ២៦ នៃច្បាប់ស្តីពីសហជីព ត្រង់កថាខណ្ឌទី ២ នៃមាត្រានេះ និងប្រកាសលេខ ៣០០ ត្រង់ប្រការ៧**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកកាត់ប្រាក់សេវាភ្នាក់ងារប្រើប្រាស់អនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ចំពោះកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីព ដោយគិតចាប់ពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - ០ នៅក្នុងក្រុមហ៊ុន មានកម្មករនិយោជិតចំនួន ៦០ភាគរយ មិនមែនជាសមាជិកសហជីព និងចំនួន ៤០ភាគរយ ជាសមាជិកសហជីព។
  - ០ ចំពោះកម្មករនិយោជិតដែលជាសមាជិកសហជីពត្រូវបង់ភាគទានសហជីពចំនួន ២ដុល្លារអាមេរិក ក្នុងមួយខែ។

- ០ អនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ បានផុតសុពលភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០១៧។ នៅក្នុងអនុសញ្ញារួមចាស់នេះ ក៏មិនមានចែងអំពីប្រាក់សេវាភ្នាក់ងារនោះទេ ហើយកន្លងមកកម្មករនិយោជិតមិនដែលទាមទារប្រាក់សេវាភ្នាក់ងារនេះដែរ។
- ភាគីកម្មករនិយោជិតបានលើកឡើងពីមូលហេតុនៃការទាមទារថា៖
  - ០ កម្មករនិយោជិតជាសមាជិកសហជីពមានភាពប្រណែន និងកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីព ពីព្រោះ នៅពេលថ្នាក់ដឹកនាំសហជីពមានអនុសញ្ញារួម ដោយដំឡើងប្រាក់ឈ្នួល ឬអត្ថប្រយោជន៍ផ្សេងៗ ពួកគាត់ដែលមិនមែនជាសមាជិកសហជីពក៏ទទួលបានផលប្រយោជន៍នឹងដូចគ្នាផងដែរ ហេតុនេះ ពួកគាត់ក៏ត្រូវតែបង់ប្រាក់សេវាភ្នាក់ងារនេះ ដូចសមាជិកសហជីពដែរ។
  - ០ យោងតាមមាត្រា ២៦ នៃច្បាប់ស្ដីពីសហជីព និងប្រកាសលេខ ៣០០ ក៏បានផ្ដល់សិទ្ធិឱ្យសហជីព ដែលមានភាពជាតំណាងបំផុតកំណត់តម្លៃសេវាភ្នាក់ងារនេះ ពីកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីព។
- ភាគីនិយោជកមិនអាចផ្ដល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា យោងតាមមាត្រា ២៦ នៃច្បាប់ស្ដីពីសហជីព និងប្រកាសលេខ ៣០០ កំណត់ថា សហជីពមានភាពតំណាងបំផុតមានសិទ្ធិចរចាជាមួយនិយោជក ដើម្បីកំណត់តម្លៃសេវាភ្នាក់ងារនេះដាក់បញ្ចូលក្នុងអនុសញ្ញារួម ករណីនេះ អនុញ្ញារួមចាស់ឆ្នាំ២០១៤-២០១៦ មិនបានកំណត់ពីប្រាក់សេវាភ្នាក់ងារនេះទេ ហើយអនុសញ្ញារួមនេះក៏បានផុតសុពលភាពហើយដែរ។ ហេតុនេះ និយោជកមិនអាចកាត់ប្រាក់សេវាភ្នាក់ងារនេះទេ។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភខែទី១៣ មួយរយភាគរយ រួមទាំងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតដែលមិនបានចុះហត្ថលេខាទទួលយកកិច្ចព្រមព្រៀងប្ដូរកិច្ចសន្យាថ្មី ដោយខុសច្បាប់ជាបន្តបន្ទាប់របស់ក្រុមហ៊ុន ព្រោះថា ប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភខែទី១៣ បុគ្គលិក ឬកម្មករនិយោជិតដែលមិនបានចុះហត្ថលេខាទទួលយកកិច្ចព្រមព្រៀងប្ដូរកិច្ចសន្យាថ្មី ទទួលបានប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភខែទី១៣ តែ ៥០ភាគរយ ប៉ុណ្ណោះ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ, ប្រាក់ឧបត្ថម្ភខែទី១៣ ចំនួន ១០០ភាគរយ និងប្រាក់ឧបត្ថម្ភថ្លៃអាហារចំនួន ៩០ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត ចាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - ០ ដោយសារបញ្ហាជំងឺកូវីដ-១៩ និយោជកមានការផ្លាស់ប្ដូរលក្ខខណ្ឌការងាររបស់កម្មករនិយោជិត ដោយអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកនៅផ្ទះ ហើយផ្ដល់ប្រាក់ឈ្នួល ៨០ភាគរយនៃប្រាក់ឈ្នួលគោល តែនៅពេលក្រុមហ៊ុនមានការងារនោះ និយោជកអាចហៅមកធ្វើការវិញបាន។ ករណីនេះ គឺមានកម្មករនិយោជិតមួយចំនួនបានយល់ព្រមទទួលយកលក្ខខណ្ឌការងារថ្មីនេះ។

- ចំពោះកម្មករនិយោជិតដែលមិនព្រមទទួលយកលក្ខខណ្ឌការងារថ្មីខាងលើ និយោជកផ្តល់ប្រាក់ឈ្នួលចំនួន ៥០ភាគរយ នៃប្រាក់ឈ្នួលគោលតែប៉ុណ្ណោះ ដោយឱ្យកម្មករនិយោជិតឈប់សម្រាកនៅផ្ទះ។
- ចំពោះប្រាក់ឧបត្ថម្ភខែទី១៣ និយោជកផ្តល់ចំនួន ២លើក ក្នុងមួយឆ្នាំ ជូនកម្មករនិយោជិត គឺលើកទី១៖ នៅខែកុម្ភៈ ចំនួន ៥០ភាគរយ នៃប្រាក់ឈ្នួលគោល និងលើកទី២៖ នៅខែសីហា ចំនួន ៥០ភាគរយ នៃប្រាក់ឈ្នួលគោល។ បន្ទាប់ពីមានការផ្លាស់ប្តូរលក្ខខណ្ឌការងារថ្មី និយោជកបានផ្តល់ប្រាក់ឧត្ថម្ភខែទី១៣ នេះ ស្របតាមចំនួនប្រាក់ឈ្នួលរបស់កម្មករនិយោជិត ចំនួន ៨០ភាគរយ ឬ៥០ភាគរយ។
- ចំពោះប្រាក់ឧបត្ថម្ភថ្លៃអាហារ និយោជកផ្តល់ជូនបុគ្គលិកផ្នែករដ្ឋបាល, ផ្នែកប្រតិបត្តិការ, និងផ្នែកអគ្គិភ័យចំនួន ២០ដុល្លារអាមេរិក ក្នុងមួយខែ ក្នុងករណីដែលពួកគាត់បានមកធ្វើការទៀងទាត់។ ក្រោយពីមានការផ្លាស់ប្តូរលក្ខខណ្ឌការងារថ្មី និយោជកក៏បានផ្តល់ប្រាក់ឧបត្ថម្ភថ្លៃអាហារចំពោះកម្មករនិយោជិត ដែលបានមកបំពេញការងារ ហើយនិយោជកមិនផ្តល់ជូនទេ ចំពោះកម្មករនិយោជិតដែលមិនបានមកបំពេញការងារ។

- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - និយោជកមានការរើសអើង ក្នុងការផ្តល់ប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភផ្សេងៗ ចំពោះកម្មករនិយោជិតដែលមិនព្រមទទួលយកលក្ខខណ្ឌការងារថ្មី។
  - និយោជកមិនមានសិទ្ធិកែប្រែលក្ខខណ្ឌការងាររបស់កម្មករនិយោជិតដែលមិនព្រមទទួលយកលក្ខខណ្ឌការងារថ្មីដោយឯកតោភាគីបានទេ។
  - និយោជកឱ្យកម្មករនិយោជិតឈប់សម្រាកនៅផ្ទះ ដោយនិយោជកមិនបានអនុវត្តការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតត្រឹមត្រូវស្របតាមមាត្រា ៧១ (១១) នៃច្បាប់ស្តីពីការងារ ហេតុនេះ ត្រូវផ្តល់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ១០០ភាគរយ ជូនកម្មករនិយោជិត។
  - យោងតាមសំណុំរឿងលេខ ០២៨/២០ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ ជូនកម្មករនិយោជិតដែលមិនព្រមទទួលយកលក្ខខណ្ឌការងារថ្មី។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - និយោជកជួបបញ្ហាសេដ្ឋកិច្ច ប្រាក់ចំណូលបានធ្លាក់ចុះ ចំនួន ៩៥ភាគរយ ក្នុងរយៈពេលប្រមាណ ៨ខែ កន្លងមកនេះ គឺនិយោជកប្រើប្រាស់ប្រាក់បំរុងទុករបស់ក្រុមហ៊ុនសុទ្ធសាធ។
  - និយោជកមិនមានការរើសអើងចំពោះកម្មករនិយោជិតដែលមិនព្រមទទួលយកលក្ខខណ្ឌការងារថ្មីនោះទេ ព្រោះមុនពេលនិយោជកផ្លាស់ប្តូរលក្ខខណ្ឌនៃកិច្ចសន្យាការងារថ្មី និយោជកបានជូនដំណឹងទៅកម្មករនិយោជិតរួចហើយ។
  - និយោជកអនុវត្តការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតតាមមាត្រា ៧១ (៦) នៃច្បាប់ស្តីពីការងារ ដោយផ្អែកតាមការព្រមព្រៀងរបស់ភាគី។

o និយោជកបានផ្តល់ប្រាក់ឧបត្ថម្ភខែទី១៣ ប្រសើរជាងបទប្បញ្ញត្តិច្បាប់។ យោងតាមបទបញ្ជាផ្ទៃក្នុងចាស់របស់ក្រុមហ៊ុន និយោជកផ្តល់ប្រាក់ឧបត្ថម្ភខែទី១៣ ស្របតាមផលចំណេញរបស់ក្រុមហ៊ុន និងយោងតាមប្រការ ១៦.៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និយោជកមានសិទ្ធិក្នុងការសម្រេចក្នុងការផ្តល់ជូន ឬកាត់បន្ថយប្រាក់ឧបត្ថម្ភខែទី១៣នេះ ហើយនិយោជកក៏បានជូនដំណឹងទៅកម្មករនិយោជិតអំពីការកែប្រែប្រាក់ឧបត្ថម្ភនេះផងដែរ។

o និយោជកផ្តល់ប្រាក់ឧបត្ថម្ភថ្លៃអាហារជូនកម្មករនិយោជិត នៅពេលពួកគាត់មកបំពេញការងារតែប៉ុណ្ណោះ។ ចំពោះថ្ងៃដែលគាត់មិនបានបំពេញការងារ និយោជកមិនផ្តល់ជូនទេ។

- យោងតាមប្រការ១៦.៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧ បានបញ្ជាក់ថា ៖ *"...ចំពោះអត្ថប្រយោជន៍ដែលក្រុមហ៊ុនបានផ្តល់ជូនដល់កម្មករនិយោជិតលើសពីច្បាប់ និងការសម្រេចចិត្តដោយផ្ទាល់របស់ខ្លួននោះ ក្រុមហ៊ុនក៏អាចសម្រេចចិត្តពិចារណាក្នុងការបង្កើត កាត់បន្ថយ ឬដកហូតអត្ថប្រយោជន៍ទាំងនោះត្រឡប់មកវិញនៅពេលណាមួយដែលចាំបាច់។ ប៉ុន្តែកម្មករនិយោជិតក៏ត្រូវបានជូនដំណឹងអំពីការផ្លាស់ប្តូរនេះ"*។

- យោងតាមឯកសាររបស់ភាគីកម្មករនិយោជិតដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ៖

  o បញ្ជីឈ្មោះកម្មករនិយោជិតសរុបចំនួន ៥៩នាក់ ដែលទាមទារប្រាក់ឧបត្ថម្ភខែទី១៣ និងប្រាក់ឧបត្ថម្ភអត្ថប្រយោជន៍ផ្សេងៗ (ថ្លៃអាហារ ៩០ដុល្លារ និងប្រាក់ជួសធ្វើការថ្ងៃបុណ្យជាតិ) ១០០% អំឡុងពេលមានការកែប្រែ ឬ និង ព្យួរកិច្ចសន្យាការងារដោយខុសច្បាប់ ដោយមានបញ្ជាក់អំពីឈ្មោះ, ភេទ, អាស័យដ្ឋាន, ផ្នែក, តួនាទី, និងសំគាល់ របស់កម្មករនិយោជិតម្នាក់ៗ។ ប៉ុន្តែ យោងតាមបញ្ជីឈ្មោះនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា មិនមានស្នាមមេដៃ ឬហត្ថលេខារបស់កម្មករនិយោជិតនោះទេ។

  o បញ្ជីឈ្មោះកម្មករនិយោជិតចំនួន ១៥នាក់ ដែលទាមទារប្រាក់ឈ្នួល ប្រាក់ឧបត្ថម្ភខែទី១៣ និងប្រាក់ឧបត្ថម្ភអត្ថប្រយោជន៍ផ្សេងៗ (ថ្លៃអាហារ ៩០ដុល្លារ និងប្រាក់ជួសធ្វើការថ្ងៃបុណ្យជាតិ) ១០០% អំឡុងពេលមានការកែប្រែ ឬ និង ព្យួរកិច្ចសន្យាការងារដោយខុសច្បាប់ ដោយបញ្ជាក់អំពីឈ្មោះ, ភេទ, អាស័យដ្ឋាន, ផ្នែក, តួនាទី, និងសំគាល់ របស់កម្មករនិយោជិតម្នាក់ៗ។ ប៉ុន្តែ យោងតាមបញ្ជីឈ្មោះនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា មិនមានស្នាមមេដៃ ឬហត្ថលេខារបស់កម្មករនិយោជិតនោះទេ។

  o នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតមិនបានលើកឡើងអំពីអំណះអំណាង អង្គហេតុ និងអង្គច្បាប់ទាក់ទងនឹងការទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ជួសធ្វើការថ្ងៃបុណ្យជាតិ ១០០ភាគរយនោះទេ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាការលើការទាមទារឱ្យនិយោជកផ្តល់ប្រាក់ជួសធ្វើការថ្ងៃបុណ្យជាតិនេះទេ។

- យោងតាមឯកសាររបស់ភាគីនិយោជក ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញមាន ៖ សំណើសុំជំទាស់ឯកសារ និងហេតុផលរបស់ភាគីសហជីពលើសំណុំរឿងលេខ ០៥៩/២០ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ បានបញ្ជាក់ថា ៖ *"... ចំពោះបញ្ជីឈ្មោះបុគ្គលិក ៥៩នាក់ និង ១៥នាក់ ដែលជាសហជីពបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទាមទារប្រាក់ខែទី១៣ និងប្រាក់ឧបត្ថម្ភប្រយោជន៍ផ្សេងៗ ១០០%*

*អំឡុងពេលមានការកែប្រែ ឬប្តូរកិច្ចសន្យាដោយខុសច្បាប់ គឺក្រុមហ៊ុនសូមបដិសេធ ដោយហេតុថា វាជាភស្តុតាងមិនពិត និងមានលក្ខណៈក្លែងបន្លំយ៉ាងពិតប្រាកដ៖ ទី១ ៖ វិវាទនេះ គឺធ្វើឡើងដោយសហជីពឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប និងសហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះភ្នំពេញប៉ុណ្ណោះ តែសហជីពទាំងពីរនេះ បានដាក់បញ្ចូលឈ្មោះបុគ្គលិកចំនួន ៤នាក់ ដែលមានមូលដ្ឋាននៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ (១. យ៉ាត ណារី ២. យិន សារិន ៣. ម៉ែន វេស្សមុនី ៤. ជី ជឿន) ចូលក្នុងបញ្ជីឈ្មោះបុគ្គលិកចំនួន ៥៩នាក់...។...បញ្ជីឈ្មោះបុគ្គលិកទាំង ៥៩នាក់ ដែលធ្វើឡើងដោយសហជីពទាំងពីរនេះ នាំឱ្យក្រុមហ៊ុនអាចសន្និដ្ឋានបានថា ជាភស្តុតាងដែលមិនអាចយកជាការបាន ដោយសារតែមិនមានការបញ្ជាក់ពីបុគ្គលិកផ្ទាល់តាមរយៈលិខិតស្នើសុំជួយដោះស្រាយ ឬស្នាមមេដៃជាដើម...មិនអាចដាក់ត្រឹមបញ្ជីឈ្មោះនេះបានទេ។...។ ទី២ ៖ ចំណែកបញ្ជីឈ្មោះបុគ្គលិក ចំនួន ១៥នាក់...ក៏មានឈ្មោះបុគ្គលិកចំនួន ៥នាក់ ដែលមានមូលដ្ឋាននៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុដែរ (១.ទន់ សុអង្គ ២.ទូច វុទ្ធី ៣. ណារី ប្រណី ៤.យឺ សុគន្ធា ៥. ដួង សុខនិល)។...។ សហជីពក៏មិនបានភ្ជាប់លិខិតចេញពីបុគ្គលិកផ្ទាល់ ឬស្នាមមេដៃរបស់បុគ្គលិកដែលបញ្ជាក់ថា ពួកគេបានស្នើសុំទៅសហជីពឱ្យជួយដោះស្រាយ...។ ក្រុមហ៊ុនសូមជំទាស់ទៅនឹងបញ្ជីឈ្មោះទាំងនេះ។"*

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកយកអនុសញ្ញារួមចាស់ឆ្នាំ២០១៤-២០១៦ មកបន្តអនុវត្តឡើងវិញរយៈពេលបីឆ្នាំបណ្តោះអាសន្ន ចាប់ពីឆ្នាំ២០២០-២០២២ ទាំងអត្ថប្រយោជន៍ និងលក្ខខណ្ឌការងារ និងប្រតិសកម្មអនុសញ្ញារួមចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចអនុវត្តអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ សម្រាប់ឆ្នាំ២០២០-២០២២ ដោយរក្សាអត្ថប្រយោជន៍និងលក្ខខណ្ឌការងារ និងប្រតិសកម្មចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ជូនកម្មករនិយោជិតដែរ ឬទេ?

យោងតាមមាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ជាក់ថា ភាគីនៃកិច្ចសន្យា អាចដាក់លក្ខខណ្ឌបង្កើត ឬការរលត់អានុភាពនៃកិច្ចសន្យានោះ។ ជាងនេះទៀត យោងតាមកថាខណ្ឌទី២ នៃមាត្រា ៣២៩ នៃក្រមរដ្ឋប្បវេណីដដែល ចែងថា ក្នុងករណីដែលមានកំណត់ពេលចប់ ចំពោះអានុភាពនៃកិច្ចសន្យា អានុភាពនោះត្រូវរលត់នៅពេលកំណត់នោះមកដល់។

យោងតាមកថាខណ្ឌទី២ នៃមាត្រា ៧០ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ប្រសិនបើអនុសញ្ញារួមត្រូវបានព្រមព្រៀងគ្នាធ្វើឡើងដោយកំណត់ចិរវេលាពិតប្រាកដ ចិរវេលានេះមានកំណត់យ៉ាងតិច ៣(បី)ឆ្នាំ។ បើដល់ពេលត្រូវបញ្ចប់កិច្ចព្រមព្រៀងហើយគ្មានភាគីណាមួយ ក្នុងចំណោមភាគីទាំងពីរធ្វើការបដិសេធ ឬសើរើអនុសញ្ញារួមក្នុងលក្ខខណ្ឌនៃការរក្សាទុកពេលជូនដំណឹងមុន ៣(បី)ខែនោះទេ អនុសញ្ញារួមនោះត្រូវចាត់ទុកថាមានតម្លៃជាធរមានក្នុងចិរវេលាដូចគ្នា"។*

យោងតាមកថាខណ្ឌទី២ នៃមាត្រា ៧០ នៃច្បាប់ស្តីពីសហជីពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំពោះអនុសញ្ញារួមដែលមានកំណត់ចិរវេលាពិតប្រាកដ ប្រសិនបើភាគីណាមួយនៃអនុសញ្ញារួមមិនបានជូនដំណឹងបដិសេធ ឬសើរើអនុសញ្ញារួមមុនរយៈពេល ៣ខែទេ នោះអនុសញ្ញារួមនៅតែមានសុពលភាពអនុវត្តដដែលក្នុងចិរវេលាដូចគ្នា។ ក្នុងករណីដែលមានការជូនដំណឹងបដិសេធ ឬសើរើមុនរយៈពេល ៣ខែ

THE ARBITRATION COUNCIL

ពីភាគីណាមួយនៃអនុសញ្ញារួម ទៅភាគីម្ខាងទៀត អនុសញ្ញារួមនេះ នឹងលែងមានសុពលភាពអនុវត្តនៅពេលដល់កាលកំណត់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ០២១/១៨-អាកាសយានដ្ឋានអន្តរជាតិ សៀមរាប ហេតុផលនៃចំណុចវិវាទទី១ បានបកស្រាយថា ៖ *"...អនុសញ្ញារួមឆ្នាំ២០១៤-២០១៦ មិនមានសុពលភាពអនុវត្តបន្តទៀតនោះទេ ពីព្រោះថា កម្មករនិយោជិត បានធ្វើការបដិសេធអនុសញ្ញារួមនោះ ក្នុងរយៈពេលមុន ៣ ខែ ដែលអនុសញ្ញារួមនេះត្រូវអស់សុពលភាព ស្របតាមបញ្ញត្តិចែងក្នុងអនុសញ្ញារួម។ សរុបមក ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត..."*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលក្នុងសំណុំរឿងមុនខាងលើដែរ។

យោងតាមអង្គហេតុ ភាគីទាំងពីរទទួលស្គាល់ថាអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ មានចិរវេលាកំណត់ចំនួន ៣ឆ្នាំ គឺចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ មុនពេលអនុសញ្ញារួមនេះផុតសុពលភាព ភាគីកម្មករនិយោជិតបានដាក់លិខិតបដិសេធអនុសញ្ញារួមចាស់នេះ ទៅនិយោ-ជក នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦។ ដោយឡែក នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិតមិនបានបដិសេធលើខ្លឹមសារនៃអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦នោះទេ គឺគ្រាន់តែបដិសេធលើបញ្ហានីតិវិធីតែប៉ុណ្ណោះ។

យោងតាមលិខិតបដិសេធអនុសញ្ញារួមចាស់ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ បានកំណត់ថា ៖ *"...កម្មវត្ថុ៖ ជំទាស់លើអនុសញ្ញារួមចាស់ ដែលនឹងត្រូវផុតកំណត់នៅបំណាច់ឆ្នាំ២០១៦ ហើយស្នើធ្វើអនុសញ្ញារួមថ្មីសំរាប់ឆ្នាំ២០១៧ ដល់២០១៩...សហជីពសុំជំទាស់លើអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ហើយមិនអាចអនុវត្តន៍បន្តទៀតបានទេ និងស្នើធ្វើអនុសញ្ញារួមថ្មី សំរាប់ឆ្នាំ២០១៧ ដល់២០១៩...សូមលោកអគ្គនាយកមេត្តាទទួលយកសេចក្តីជំទាស់ និងសំណើខាងលើរបស់តំណាងកម្មករនិយោជិតដោយក្តីអនុគ្រោះ..."*។

យោងតាមខ្លឹមសារនៃលិខិតខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លិខិតខាងលើនេះ បានបញ្ជាក់យ៉ាងច្បាស់ថា សហជីពពិតជាបានសុំបដិសេធខ្លឹមសារអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ដោយសុំមិនអនុវត្តអនុសញ្ញារួមចាស់នេះរួចហើយ ហើយសុំឱ្យភាគីនិយោជកចរចាធ្វើអនុសញ្ញារួមថ្មីជំនួសវិញ ពោល គឺមិនមែនជាលិខិតបដិសេធតែលើបញ្ហានីតិវិធីនោះទេ។ ហេតុនេះ យោងតាមកថាខណ្ឌទី២ នៃមាត្រា ៧០ នៃច្បាប់ស្តីពីសហជីពខាងលើ អនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ គឺត្រូវបានផុតសុពលភាពនៅពេលដល់កាលកំណត់ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ហើយមិនអាចយកមកអនុវត្តបានទៀតនោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកយកអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ មកបន្តអនុវត្តឡើងវិញរយៈពេលបីឆ្នាំបណ្តោះអាសន្ន ចាប់ពីឆ្នាំ ២០២០-២០២២ ទាំងអត្ថប្រយោជន៍ និងលក្ខខណ្ឌការងារ និងប្រតិសកម្មអនុសញ្ញារួមចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកកាត់ប្រាក់សេវាភ្នាក់ងារប្រើប្រាស់អនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ចំពោះកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីព ដោយគិតចាប់ពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចកាត់ប្រាក់សេវាភ្នាក់ងារប្រើប្រាស់

THE ARBITRATION COUNCIL

អនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ចំពោះកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីព ដោយគិតចាប់ពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្នដែរ ឬទេ?

កថាខណ្ឌទី២ មាត្រា ២៦ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា៖ *"សហជីពមានភាពជាតំណាងបំផុតដែលតំណាងឱ្យកម្មករនិយោជិតទាំងអស់មានសិទ្ធិផ្តាច់មុខក្នុងការចរចា ដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួម នូវការកំណត់តម្លៃសេវាភ្នាក់ងារសេមម្យេងកភាពមួយ ដែលមិនលើសប្រាក់ភាគទាន និងតម្លៃផ្សេងទៀត។ តម្លៃសេវាភ្នាក់ងារនេះ ត្រូវបានបង់តែម្តងគត់"*។

កថាខណ្ឌទី១ ប្រការ ៧ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ ចែងថា៖ *"សហជីពមានភាពជាតំណាងបំផុតមានសិទ្ធិផ្តាច់មុខក្នុងការចរចាដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួម នូវការកំណត់តម្លៃសេវាភ្នាក់ងារសេមម្យេងកភាពមួយដែលមិនលើសប្រាក់ភាគទានប្រចាំខែរបស់សមាជិកខ្លួន។ តម្លៃសេវាភ្នាក់ងារនេះ ត្រូវបានបង់តែម្តងគត់"*។

យោងតាមកថាខណ្ឌទី២ មាត្រា ២៦ នៃច្បាប់ស្តីពីសហជីព និងកថាខណ្ឌទី១ ប្រការ ៧ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែសហជីពមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិចរចាជាមួយនិយោជក ក្នុងការដាក់បញ្ចូលតម្លៃសេវាភ្នាក់ងារទៅក្នុងអនុសញ្ញារួម ហើយតម្លៃសេវាភ្នាក់ងារនេះមិនអាចលើសពីប្រាក់ភាគទានប្រចាំខែរបស់សមាជិកសហជីពបានឡើយ និងត្រូវបង់តែម្តងគត់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការចរចាតម្លៃសេវាភ្នាក់ងារបញ្ចូលទៅក្នុងអនុសញ្ញារួមនេះ គឺត្រូវធ្វើឡើងនៅក្នុងអំឡុងពេលដែលភាគីទាំងពីរកំពុងតែចរចាបង្កើតអនុសញ្ញារួម។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅក្នុងអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ គឺត្រូវបានចរចាចប់សព្វគ្រប់ហើយ ជាមួយគ្នានេះ នៅក្នុងអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ក៏មិនមានខណាមួយចែងអំពីប្រាក់សេវាភ្នាក់ងារនោះទេ ម្យ៉ាងទៀត អនុសញ្ញារួមចាស់នេះ ត្រូវបានផុតសុពលភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ មកម្លេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចកាត់ប្រាក់សេវាភ្នាក់ងារប្រើប្រាស់អនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ចំពោះកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីព ចាប់ពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ននោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកកាត់ប្រាក់សេវាភ្នាក់ងារប្រើប្រាស់អនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ចំពោះកម្មករនិយោជិតមិនមែនជាសមាជិកសហជីព ដោយគិតចាប់ពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ, ប្រាក់ឧបត្ថម្ភខែទី១៣ ចំនួន ១០០ភាគរយ និងប្រាក់ឧបត្ថម្ភថ្លៃអាហារចំនួន ៩០ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត ចាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ**

ករណីនេះ ភាគីកម្មករនិយោជិតបានដាក់បញ្ជីឈ្មោះកម្មករនិយោជិតចំនួន ៥៩នាក់ ដែលទាមទារប្រាក់ឧបត្ថម្ភខែទី១៣ ចំនួន ១០០ភាគរយ និងប្រាក់ឧបត្ថម្ភថ្លៃអាហារចំនួន ៩០ដុល្លារអាមេរិក ក្នុងមួយខែ និងកម្មករនិយោជិតចំនួន ១៥នាក់ ដែលទាមទារប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភខែទី១៣ ចំនួន ១០០ភាគរយ និងប្រាក់ឧបត្ថម្ភថ្លៃអាហារចំនួន ៩០ដុល្លារអាមេរិក ក្នុងមួយខែ។ ភាគីនិយោជកបានជំទាស់បញ្ជីឈ្មោះកម្មករនិយោជិតថា ជាភស្តុតាងដែលមិនអាចយកជាការបាន ដោយសារមិនមានការបញ្ជាក់ពីកម្មករនិយោជិតផ្ទាល់តាមរយៈលិខិតស្នើសុំជួយដោះស្រាយ ឬស្នាមមេដៃ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើសហជីពមានភាពជាតំណាងបំផុតមានសិទ្ធិតំណាងឱ្យកម្មករនិយោជិតនៅក្នុងការទាមទារចំណុចវិវាទនេះបានដែរ ឬទេ?

យោងតាមមាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ចែងថា ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យាដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺធ្វើសម្រាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង។ ក្នុងន័យនេះ សិទ្ធិតំណាងកើតឡើងតាមរយៈកិច្ចសន្យា រវាងម្ចាស់សិទ្ធិ និង អ្នកតំណាង (មាត្រា ៣៦៥ នៃក្រមរដ្ឋប្បវេណី)។

ជាងនេះទៀត យោងតាមកថាខណ្ឌទី១ នៃមាត្រា ៥៤-ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ (តទៅហៅថា មាត្រា ៥៤-ថ្មី នៃច្បាប់ស្តីពីសហជីព) ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីព ត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។"*

ប្រការ ១៣ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ចែងថា៖ *"សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួម ដែលកើតចេញពីខចែងទាំងឡាយក្នុងអនុសញ្ញារួម។*

*សហជីពដែលមានភាពជាតំណាងបំផុតមានករណីកិច្ច ដូចខាងក្រោម ៖*

- *...*
- *ធ្វើជាតំណាងដោយស្មោះត្រង់ឱ្យកម្មករនិយោជិត ដែលមិនមែនជាសមាជិករបស់ខ្លួននៅក្នុងបណ្តឹងតវ៉ាមិនសុខចិត្តដែលកើតចេញពីអនុសញ្ញារួម*
- *ធ្វើជាតំណាងដោយស្មោះត្រង់ឱ្យកម្មករនិយោជិតចំពោះវិវាទផ្សេងៗទៀត ដែលមិនកើតចេញពីអនុសញ្ញារួម តាមសំណើរបស់កម្មករនិយោជិត ឬសហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស គ្រឹះស្ថាន*
- *...។"*

យោងតាមកថាខណ្ឌទី១ នៃមាត្រា ៥៤-ថ្មី នៃច្បាប់ស្តីពីសហជីព និងប្រការ១៣ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួម ដែលកើតចេញពីខទាំងឡាយដែលមានចែងក្នុងអនុសញ្ញារួម។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតដែលមិនមែនជាសមាជិករបស់ខ្លួននៅក្នុងបណ្តឹងតវ៉ាដែលកើតចេញពីអនុសញ្ញារួម និងសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតក្នុងការដោះស្រាយវិវាទក្រៅពីអនុសញ្ញារួម តាមការស្នើសុំរបស់កម្មករនិយោជិត ឬសហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។

ករណីនេះ ភាគីកម្មករនិយោជិតបានដាក់បញ្ជីឈ្មោះកម្មករនិយោជិតជាដើមបណ្តឹង ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ប៉ុន្តែ យោងតាមបញ្ជីឈ្មោះនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា មិនមានហត្ថលេខា ឬស្នាមមេដៃរបស់កម្មករនិយោជិតបញ្ជាក់ការទាមទារនៅក្នុងលិខិតនោះទេ។

ជាមួយគ្នានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុចវិវាទនេះ គឺមិនមែនជាចំណុចវិវាទដែលកើតចេញពីអនុសញ្ញារួមនោះទេ ពោលគឺជាចំណុចវិវាទក្រៅពីអនុសសញ្ញារួម ដោយហេតុថា ចំណុចវិវាទនេះ គឺទាក់ទងនឹងបញ្ហាប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់កម្មករនិយោជិតនីមួយៗ ស្របតាមកិច្ចសន្យាការងាររបស់ពួកគេ បន្ទាប់ពីនិយោជកមានការផ្លាស់ប្តូរលក្ខខណ្ឌការងារថ្មី ហេតុនេះ ចំណុចទាមទារនេះ គឺត្រូវមានលិខិតស្នើសុំ ឬលិខិតបញ្ជាក់ការទាមទារដែលមានហត្ថលេខា ឬស្នាមមេដៃផ្ទាល់ពីកម្មករនិយោជិតដែលរងការខូចខាត ឬមានផលប្រយោជន៍ដោយផ្ទាល់។

ប៉ុន្តែ ក្នុងករណីចំនុចវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញលិខិតផ្ទេរសិទ្ធិតំណាង ឬលិខិតបញ្ជាក់ការទាមទារដែលមានហត្ថលេខា ឬស្នាមមេដៃរបស់កម្មករនិយោជិតនោះទេ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទោះបីជាសហជីពមានភាពជាតំណាងបំផុត ក៏មិនមានសិទ្ធិធ្វើជាតំណាងឱ្យកម្មករនិយោជិតក្នុងការទាមទារនៅក្នុងចំណុចវិវាទនេះនោះទេ ដោយពុំមានការពឹងពាក់ ឬផ្ទេរសិទ្ធិតំណាងដោយផ្ទាល់ពីកម្មករនិយោជិតនីមួយៗដែរ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ, ប្រាក់ឧបត្ថម្ភខែទី១៣ ចំនួន១០០ ភាគរយ និងប្រាក់ឧបត្ថម្ភថ្លៃអាហារចំនួន ៩០ដុល្លារអាមេរិក ជូនកម្មករនិយោជិត ចាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ។

យោងតាមការបង្ហាញកស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី ១ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកយកអនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ មកបន្តអនុវត្តឡើងវិញរយៈពេលបីឆ្នាំបណ្តោះអាសន្ន ចាប់ពីឆ្នាំ២០២០-២០២២ ទាំងអត្ថប្រយោជន៍ និងលក្ខខណ្ឌការងារ និងប្រតិសកម្មអនុសញ្ញារួម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០។

**ចំណុចវិវាទទី ២ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកកាត់ប្រាក់សេវាភ្នាក់ងារប្រើប្រាស់អនុសញ្ញារួមចាស់ ឆ្នាំ២០១៤-២០១៦ ចំពោះកម្មករនិយោជិតមិនមែនជាសមាជិកសហជីព ដោយគិតចាប់ពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន។

**ចំណុចវិវាទទី ៣ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ, ប្រាក់ឧបត្ថម្ភខែទី១៣ ចំនួន ១០០ភាគរយ និងប្រាក់ឧបត្ថម្ភថ្លៃអាហារចំនួន ៩០ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត ចាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **លី តៃសេង**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ទួន ស៊ីផាន់**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL

**ឧបសម្ព័ន្ធនៃសេចក្តីបង្គាប់លេខ ០៥៩/២០-ខេមបូឌា អ៊ែរផត មែនីជ្មែន សឺវីស**

# យោបល់ជំទាស់ទៅលើសេចក្តីសម្រេច
# សំណុំរឿងលេខ ០៥៩/២០ - ខេមបូឌា អ៊ែរផត មែនីជ្មែន សឺវីស
# ដោយអាជ្ញាកណ្តាល ទូន ស៊ីផាន់ ដែលជ្រើសរើសដោយភាគីសហជីពកម្មករនិយោជិត

ប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចែងថា *"ក្រុមអាជ្ញាកណ្តាលត្រូវកត់ត្រាពាល់សេចក្តីសម្រេចរបស់ខ្លួនក្នុងសេចក្តីបង្គាប់មួយ ដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្តាលទាំង ០៣រូប។ ក្នុងករណីដែលអាជ្ញាកណ្តាលណាម្នាក់ មិនឯកភាពនឹងសេចក្តីសម្រេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយ ក្នុងសេចក្តីបង្គាប់នោះ "*។

យោងតាមប្រការនេះ ខ្ញុំអាជ្ញាកណ្តាល **ទូន ស៊ីផាន់** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងហេតុផលនៃសេចក្តីសម្រេចនៃសេចក្តីបង្គាប់លេខ ០៥៩/២០-ខេមបូឌា អ៊ែរផត មែនីជ្មែន សឺវីស ត្រង់ចំណុចវិវាទទី៣ (ចំណុចទី១ និងចំណុចទី២) ដែលអាជ្ញាកណ្តាលពីររូបទៀត បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ, ប្រាក់ឧបត្ថម្ភខែទី១៣ ចំនួន ១០០ភាគរយ ជូនកម្មករនិយោជិត ចាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃ ចូលធ្វើការវិញ។

**ចំពោះការផ្តិតមេដៃទាមទាររបស់ភាគីកម្មករនិយោជិត**

គូភាគីនៅក្នុងសំណុំរឿងនេះ គឺជាគូភាគីដដែល នៃសំណុំរឿងលេខ ០២៨/២០-អាកាសយានដ្ឋានកម្ពុជា (CAMS) ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០។ នៅក្នុងសំណុំរឿងនោះ មានកម្មករនិយោជិតចំនួន ១៥០(មួយរយហាសិប)នាក់ បានផ្តិតមេដៃពឹងពាក់សហជីពឱ្យជួយរកដំណោះស្រាយការទាមទាររបស់ខ្លួន ជាមួយនិយោជក ដែលនៅក្នុងនោះ ក៏មានកម្មករនិយោជិត ៥៩នាក់ នេះផងដែរ។ ការទាមទារប្រាក់ឈ្នួលលើកមុន គឺសម្រាប់តែខែមេសា និងខែឧសភា ឆ្នាំ២០២០ តែប៉ុណ្ណោះ។ ការទាមទារលើកនេះ គឺកម្មករនិយោជិតបានធ្វើបញ្ជីឈ្មោះ តែកម្មករនិយោជិត ៥៩នាក់ ដែលមិនបានចុះហត្ថលេខាទទួលយកកិច្ចព្រមព្រៀងប្តូរកិច្ចសន្យាថ្មី ដែលបានទាមទារបន្តពីខែមិថុនា ឆ្នាំ២០២០ មកដល់ពេលបច្ចុប្បន្ន។

ដូចនេះ ភាគីកម្មករនិយោជិត នៅតែមានសិទ្ធិទាមទារប្រាក់ឈ្នួល ប្រាក់ខែទី១៣ ប្រាក់ឧត្ថម្ភអាហារប្រចាំខែ និងអត្ថប្រយោជន៍ផ្សេងៗ ឱ្យកម្មករនិយោជិតក្នុងសំណុំរឿងនេះ។

**១- ចំពោះប្រាក់ឈ្នួល១០០%**

នៅក្នុងអង្គហេតុ ក្រុមអាជ្ញាកណ្តាលបានរកឃើញថា ដោយសារបញ្ហាជំងឺកូវីដ-១៩ និយោជកមានការផ្លាស់ប្តូរលក្ខខណ្ឌការងាររបស់កម្មករនិយោជិត ដោយអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកនៅផ្ទះ ចាប់ពីខែមេសា ឆ្នាំ២០២០ តាមលក្ខខណ្ឌដូចខាងក្រោម៖

- និយោជកផ្តល់ប្រាក់ឈ្នួលចំនួន ៨០ភាគរយ នៃប្រាក់ឈ្នួលគោល ចំពោះកម្មករនិយោជិតណាដែលបានយល់ព្រមចុះហត្ថលេខាទទួលយកលក្ខខណ្ឌការងារថ្មីនេះ ដោយមានលក្ខខណ្ឌថា ត្រូវ

THE ARBITRATION COUNCIL

ផ្តល់លេខទូរស័ព្ទ និងអាសយដ្ឋានទាក់ទងច្បាស់លាស់ ហើយនៅពេលណាក្រុមហ៊ុនមានការងារឱ្យធ្វើ នោះនិយោជកអាចហៅទៅធ្វើការវិញ តាមការចាំបាច់នោះបាន។

- ចំពោះកម្មករនិយោជិតដែលមិនព្រមទទួលយកលក្ខខណ្ឌការងារថ្មីខាងលើ និយោជកផ្តល់ប្រាក់ឈ្នួលចំនួន ៥០ភាគរយ នៃប្រាក់ឈ្នួលគោល ដោយឱ្យកម្មករនិយោជិតឈប់សម្រាកនៅផ្ទះ និងមិនបាច់ហៅទៅធ្វើការម្តងម្កាលនោះទេ។

ភាគីកម្មករនិយោជិតអះអាងថា និយោជកឱ្យកម្មករនិយោជិតឈប់សម្រាកនៅផ្ទះ ដោយនិយោជកមិនបានអនុវត្តការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតត្រឹមត្រូវ ស្របតាមមាត្រា៧១(១១) នៃច្បាប់ស្តីពីការងារ ហេតុនេះ និយោជកត្រូវផ្តល់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ១០០ភាគរយ ជូនកម្មករនិយោជិត។

ភាគីនិយោជកអះអាងថា ខ្លួនមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា និយោជកជួបបញ្ហាសេដ្ឋកិច្ច ប្រាក់ចំណូលចំនួន ៩៥ភាគរយ បានធ្លាក់ចុះក្នុងរយៈពេលចំនួន ប្រមាណជា ៨ខែ កន្លងមកនេះ គឺនិយោជកប្រើប្រាស់ប្រាក់បំរុងទុករបស់ក្រុមហ៊ុនសុទ្ធសាធ។ និយោជកមិនមានការរើសអើងចំពោះកម្មករនិយោជិតដែលមិនព្រមទទួលយកលក្ខខណ្ឌការងារថ្មីនោះទេ ព្រោះមុនពេលនិយោជកផ្លាស់ប្តូរលក្ខខណ្ឌនៃកិច្ចសន្យាការងារថ្មី និយោជកបានជូនដំណឹងទៅកម្មករនិយោជិតរួចហើយ។ និយោជកអនុវត្តការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតតាមមាត្រា៧១(៦) នៃច្បាប់ស្តីពីការងារ ឱ្យកម្មករនិយោជិតឈប់សម្រាកនៅផ្ទះនេះ ដោយផ្អែកតាមស្ថានភាពនៃជំងឺកូវីដ-១៩ និងខ្លះទៀត តាមការព្រមព្រៀងរបស់ភាគី។

យោងតាមសំណុំរឿងលេខ ០២៨/២០ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ ជូនកម្មករនិយោជិតដែលមិនព្រមទទួលយកលក្ខខណ្ឌការងារថ្មី។

កម្មករនិយោជិតទាំង ៥៩នាក់នេះ សុទ្ធតែជាអ្នកដែលមិនបានចុះហត្ថលេខាទទួលយកកិច្ចព្រមព្រៀងប្តូរកិច្ចសន្យាថ្មីនេះ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿលេខ ០២៨/២០-អាកាសយានដ្ឋានកម្ពុជា(CAMS) ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ ត្រង់ចំណុចវិវាទទី១ បានបង្គាប់ឱ្យភាគីនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យពួកគាត់ពេញ ១០០% សម្រាប់ខែមេសា និងខែឧសភា ឆ្នាំ២០២០ តាមការទាមទាររបស់ភាគីកម្មករនិយោជិត។ (សូមមើលសេចក្តីបង្គាប់នៃសំណុំរឿលេខ ០២៨/២០-អាកាសយានដ្ឋានកម្ពុជា(CAMS) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ ត្រង់ចំណុចវិវាទទី១)។

ដោយសារការទាមទាររបស់ភាគីកម្មករនិយោជិតនៅក្នុងសំណុំរឿងនេះ មានលក្ខខណ្ឌ ស្ថានភាព អង្គហេតុ និងអង្គច្បាប់ដដែល ដូចនេះ ភាគីកម្មករនិយោជិតនៅតែត្រូវទទួលបានប្រាក់ឈ្នួលពេញ ១០០% ចាប់ពីខែមិថុនា ឆ្នាំ២០២០ មកដល់បច្ចុប្បន្ន។

**២- ចំពោះប្រាក់ខែទី១៣**

នៅក្នុងអង្គហេតុ ក្រុមអាជ្ញាកណ្តាលបានរកឃើញថា និយោជកបានចាប់ផ្តើមផ្តល់ប្រាក់ឧបត្ថម្ភខែទី១៣នេះ ឱ្យកម្មករនិយោជិត ចាប់តាំងពីឆ្នាំ២០០៤មក ដោយផ្តល់ជាចំនួន២(ពីរ)លើក

THE ARBITRATION COUNCIL

ក្នុងមួយឆ្នាំ ជូនកម្មករនិយោជិត គឺលើកទី១៖ នៅខែកុម្ភៈចំនួន ៥០ភាគរយ នៃប្រាក់ឈ្នួលគោល និងលើកទី២៖ នៅខែសីហាចំនួន ៥០ភាគរយ នៃប្រាក់ឈ្នួលគោល។ បន្ទាប់ពីមានការផ្លាស់ប្តូរលក្ខខណ្ឌការងារថ្មី និយោជកបានផ្តល់ប្រាក់ឧត្តម្ភខែទី១៣នេះ ស្របតាមចំនួនប្រាក់ឈ្នួលរបស់កម្មករនិយោជិតតាម គឺចំនួន ៨០ភាគរយ ឬ ៥០ភាគរយ។ ចំពោះអ្នកដែលនៅធ្វើការពេញម៉ោង និយោជកនៅផ្តល់ឱ្យ ១០០% ដដែល។

និយោជកអះអាងថា ខ្លួនបានផ្តល់ប្រាក់ឧបត្ថម្ភខែទី១៣ ប្រសើរជាងបទប្បញ្ញត្តិច្បាប់។ យោងតាមបទបញ្ជាបញ្ជាផ្ទៃក្នុងចាស់របស់ក្រុមហ៊ុន និយោជកផ្តល់ប្រាក់ឧបត្ថម្ភខែទី១៣ ស្របតាមផលចំណេញរបស់ក្រុមហ៊ុន និងយោងតាមប្រការ១៦.៤ បញ្ញានៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និយោជកមានសិទ្ធិក្នុងការសម្រេចក្នុងការផ្តល់ជូន, កាត់បន្ថយប្រាក់ឧបត្ថម្ភខែទី១៣នេះ ហើយនិយោជកក៏បានជូនដំណឹងទៅកម្មករនិយោជិតអំពីការកែប្រែប្រាក់ឧបត្ថម្ភនេះផងដែរ។

ប្រាក់ខែទី១៣នេះ និយោជកបានផ្តល់ឱ្យកម្មករនិយោជិតតាំងពីឆ្នាំ២០០៤មក ដែលគិតដល់សព្វថ្ងៃ មានរយៈពេល ១៦(ដប់ប្រាំមួយ)ឆ្នាំមកហើយ ដែលការអនុវត្តនេះ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនផងដែរ។ សព្វថ្ងៃនេះ ចំពោះកម្មករនិយោជិតដែលទៅធ្វើការជាធម្មតា និយោជកនៅតែផ្តល់ប្រាក់ឧបត្ថម្ភខែទី១៣ ចំនួន ១០០ភាគរយ។ ការអនុវត្តក្នុងរយៈដ៏យូរនេះ បានបង្កើតជាសិទ្ធិដែលកម្មករនិយោជិតត្រូវទទួលបានពេញជាបន្តទៀត ដូចប្រាក់ខែដែរ។

អាស្រ័យហេតុនេះ ភាគីកម្មករនិយោជិតក៏ត្រូវទទួលបានប្រាក់ខែទី១៣នេះពេញ១០០%ដែរ។

**ដូចនេះ ខ្ញុំយល់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលគួរតែពិចារណា និងសម្រេចចេញសេចក្តីបង្គាប់ចំពោះចំណុចវិវាទទី៣នេះ ដូចខាងក្រោម៖**

**៣(១)-បង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលពេញចំនួន ១០០% ដល់កម្មករនិយោជិត ៥៩នាក់ ដែលមិនបានចុះហត្ថលេខាយល់ព្រមទទួលយកការកែប្រែលក្ខខណ្ឌការងារថ្មី ចាប់ពីខែមិថុនា ឆ្នាំ២០២០ មកដល់បច្ចុប្បន្ន។**

**៣(២)-បង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ខែទី១៣ពេញ ចំនួន ១០០% ដល់កម្មករនិយោជិត ៥៩នាក់ ដែលមិនបានចុះហត្ថលេខាយល់ព្រមទទួលយកការកែប្រែលក្ខខណ្ឌការងារថ្មីនេះ។**

ថ្ងៃចន្ទ ៨កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០

**ហត្ថលេខារបស់អាជ្ញាកណ្តាល**

THE ARBITRATION COUNCIL

**ឌុន ស៊ីផាន់**